**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៧៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៤៤៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់ប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

**សម្រេច**

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

ត្រូវបានបង្កើត "**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**" សរសេរជាអក្សរកាត់ថា "**គ.ហ.ស.**"។



www.pheakdeylaw.com

**គ.ហ.ស.** មានភារកិច្ចដឹកនាំ រៀបចំ សម្របសម្រួលការអនុវត្ត តាមដាន និងត្រួតពិនិត្យការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ព្រមទាំងសម្របសម្រួលកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ដែលមានការពាក់ព័ន្ធ។

## ជំពូកទី២
## សមាសភាពនិងរចនាសម្ព័ន្ធ

**មាត្រា២.-**

**គ.ហ.ស.** មានសមាសភាពដូចតទៅ÷

| | | |
|---|---|---|
| ១- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | | ប្រធាន |
| ២- រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | មួយរូប | អនុប្រធានប្រចាំការ |
| ៣- ទេសាភិបាលរងនៃធនាគារជាតិនៃកម្ពុជា | មួយរូប | អនុប្រធាន |
| ៤- រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ឬថ្នាក់ដឹកនាំប្រហាក់ប្រហែលមួយរូប ពីគ្រប់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ | | សមាជិក |
| ៥- អគ្គលេខាធិការនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | | សមាជិក |
| ៦- ប្រធានអង្គភាពប្រតិបត្តិនៃគណៈកម្មាធិការ ដឹកនាំការងារកែទម្រង់ដែលមានការពាក់ព័ន្ធផ្សេងទៀត | | សមាជិក |
| ៧- អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការ ដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | | សមាជិកអចិន្ត្រៃយ៍។ |

សមាសភាពជាក់ស្តែងនៃ **គ.ហ.ស.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា៣.-**

ដើម្បីធានាប្រសិទ្ធភាពនិងភាពស័ក្តិសិទ្ធិនៃការបំពេញភារកិច្ចរបស់ **គ.ហ.ស.** ដូចមានចែងក្នុងមាត្រា១ នៃអនុក្រឹត្យនេះ គ្រប់ក្រសួង ស្ថាប័ន និងអង្គភាពដែលមានការពាក់ព័ន្ធ ត្រូវរៀបចំបង្កើត "**ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**" មួយនៅក្នុងក្រសួង ស្ថាប័ន និងអង្គភាពរបស់ខ្លួន។ ក្រុមការងារនេះ ត្រូវស្ថិតនៅក្រោមការដឹកនាំផ្ទាល់របស់តំណាងនៃក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ដែលជាសមាជិក **គ.ហ.ស.**។

ប្រធាន **គ.ហ.ស.** ត្រូវរៀបចំសេចក្តីណែនាំស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមការងារនេះ ជូនដល់គ្រប់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបង្កើត "**គណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**" មួយដែលត្រូវស្ថិតក្រោមការដឹកនាំផ្ទាល់របស់ប្រធាន **គ.ហ.ស.** ដើម្បីសម្របសម្រួលការរៀបចំ ការអនុវត្ត ការតាមដាន និងត្រួតពិនិត្យការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅក្នុងក្របខណ្ឌនៃសមត្ថកិច្ចផ្ទាល់របស់ក្រសួង។



www.pheakdeylaw.com

## ជំពូកទី៣
## ដំណើរការការងារ

**មាត្រា៤.-**

តាមការអញ្ជើញរបស់ប្រធាន សមាជិក និងអនុប្រធាន **គ.ហ.ស.** ត្រូវចូលរួមប្រជុំ ឬចាត់តាំងតំណាងដែលមានសិទ្ធិសម្រេចជំនួស ដើម្បីចូលរួមប្រជុំ ក្នុងករណីអវត្តមាន ឬមានធុរៈ។

**មាត្រា៥.-**

គ.ហ.ស. មានសិទ្ធិអញ្ជើញមន្ត្រីផ្សេងទៀតនៃក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ចូលរួមប្រជុំ តាមការចាំបាច់។

គ.ហ.ស. មានសិទ្ធិអញ្ជើញតំណាងដៃគូអភិវឌ្ឍន៍ តំណាងវិស័យឯកជន និងតំណាងសង្គមស៊ីវិល ចូលរួមប្រជុំ ក្នុងឋានៈជាសមាជិក ឬអ្នកសង្កេតការណ៍ តាមការចាំបាច់។

**មាត្រា៦.-**

**គ.ហ.ស.** មានអគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយ នៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាសេនាធិការ សម្រាប់បំពេញមុខងាររបស់ខ្លួន។

ការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាន **គ.ហ.ស.** ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាន គ.ហ.ស.។

គ.ហ.ស. ប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ដំណើរការការងារ។

## ជំពូកទី៤
## អន្តរប្បញ្ញត្តិ

**មាត្រា៧.-**

រចនាសម្ព័ន្ធរបស់ **គ.ហ.ស.** ដែលត្រូវបានបង្កើតឡើងដោយអនុលោមតាមសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាល លេខ ៥៦ សសរ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៧ ត្រូវបន្តនិរន្តរភាពការងាររបស់ខ្លួន រហូតដល់មានការរៀបចំថ្មី ដោយអនុលោមតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។



www.pheakdeylaw.com

**មាត្រា៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័ន ដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាប

ជូនសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**ប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- -ដូចមាត្រា៩
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ



www.pheakdeylaw.com